# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីថ្លែងការណ៍របស់គណៈកម្មការប្រឹក្សាការងារ

ឆ្នាំ២០១២ ខែកក្កដា ថ្ងៃទី១១ វេលាម៉ោង ៨:៣០ ព្រឹក មានកិច្ចប្រជុំគណៈកម្មការប្រឹក្សាការងារ អណត្តិទី ៨ លើកទី ២ នៅសាលប្រជុំរបស់បេឡាជាតិរបបសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ពិភាក្សាអំពីការផ្តល់អត្ថប្រយោជន៍ផ្សេងៗសម្រាប់កម្មករនិយោជិតធ្វើការនៅផ្នែកវាយនភ័ណ្ឌ កាត់ដេរ និងផលិតស្បែកជើង។ ក្រោយពីបានពិគ្រោះយោបល់យ៉ាងផុលផុសនិងគ្រប់ជ្រុងជ្រោយ គណៈកម្មការប្រឹក្សាការងារបានឯកភាពគ្នាដូចតទៅ ៖

១-ផ្តល់ប្រាក់សោហ៊ុយធ្វើដំណើរ និងថ្លៃស្នាក់នៅចំនួន ៧ ដុល្លារសហរដ្ឋអាមេរិក ក្នុងមួយខែ។

ចំពោះកម្មករនិយោជិតណាដែលនិយោជកបានផ្តល់មធ្យោបាយធ្វើដំណើរ ឬផ្តល់កន្លែងស្នាក់នៅរួចហើយ គឺមិនត្រូវទទួលបាននូវប្រាក់សោហ៊ុយធ្វើដំណើរ និងថ្លៃស្នាក់នៅនេះទេ។ ហើយបើនិយោជកណាបានផ្តល់ប្រាក់សោហ៊ុយធ្វើដំណើរ និងថ្លៃស្នាក់នៅល្អប្រសើរជាងការកំណត់នេះ ត្រូវរក្សានៅដដែល។

២-ផ្តល់ប្រាក់រង្វាន់ធ្វើការទៀងទាត់ចំនួន១០ ដុល្លារសហរដ្ឋអាមេរិកក្នុងមួយខែ។ ចំពោះរោងចក្រ សហគ្រាស គ្រឹះស្ថានណាដែលបានផ្តល់ប្រាក់រង្វាន់លើសពីការកំណត់នេះ ត្រូវរក្សាប្រាក់រង្វាន់ដែលឲ្យលើសនោះ នៅដដែល។

៣-ចំណុចទី១ នៃសេចក្តីជូនដំណឹង លេខ ០៤១/១១ កប/សជណ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១១ ត្រូវចាត់ទុកជានិរាករណ៍។

ការផ្តល់អត្ថប្រយោជន៍ផ្សេងៗ ដូចមានចែងក្នុងចំណុចទី១ និងទី២ នៃសេចក្តីថ្លែងការណ៍នេះត្រូវអនុវត្តចាប់ពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១២ តទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១២

**ប្រធានគណៈកម្មការប្រឹក្សាការងារ**

**វង សូត**

**អនុប្រធានគណៈកម្មការ**
**ប្រឹក្សាការងារ តាតីតំណាងនិយោជក**

**ឧកញ៉ា បណ្ឌិត ណាង សុធី**

**អនុប្រធានគណៈកម្មការ**
**ប្រឹក្សាការងារ តាតីតំណាងកម្មករនិយោជិត**

**ជួន មុំថុល**